នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Jun-2015, 15:43
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបញ្ជីឯកសារសាក្សី សម្រាប់ សាក្សី SCW-3, SCW-4 និង SCW-5

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA- MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Anta GUISSÉ
លោក Arthur VERCKEN

**មេធាវីប្រចាំការ:**
លោកស្រី ទូច វលក្ស
លោក Calvin SAUNDERS

# ចម្លើយតប

## *I. ប្រវត្តិនីតិវិធី*

1. នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ អង្គជំនុំជម្រះតុលាការកំពូល("អជតក") បានកំណត់កាលបរិច្ឆេទសម្រាប់សវនាការចំពោះសាក្សីទាំងបីដែលបានស្នើឡើងដោយ នួន ជា ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០១[1]។ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ អជតក បានបង្គាប់ឲ្យភាគីនៃសំណុំរឿង០០២ ដាក់ត្រឹមថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ តាមរយៈសារអេឡិចត្រូនិច(អ៊ីម៉េល) នូវ "បញ្ជីសម្ភារៈដែលភាគីមានបំណងចង់ប្រើប្រាស់ នៅក្នុងអំឡុងនៃការសួរដេញដោលសាក្សីទាំងបីរូប"[2]។ អជតក ក៏បានណែនាំដល់ភាគីផងដែរឲ្យដាក់ត្រឹមថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ នូវការជំទាស់ណាមួយទៅនឹងឯកសារទាំងនេះដែលបានដាក់ដោយភាគីដទៃ[3]។ តាមសំណើរបស់ ខៀវ សំផន ការកំណត់ពេលចុងក្រោយសម្រាប់ដាក់ឯកសារនោះ ត្រូវបានពន្យារដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥[4]។ អជតក បានថ្លែងបន្ថែមថា វៀរលែងតែក្នុងកាលៈទេសៈពិសេស ខ្លួនមិនអាច "ទទួលយកការជំទាស់ណាមួយទៅនឹងឯកសារដែលបានប្រើប្រាស់នៅក្នុងអំឡុងនៃការសួរដេញដោលសាក្សីដែលបានលើកនាំដំណាក់កាលក្រោយៗទៀត រួមទាំងនៅក្នុងសវនាការដែលបានកំណត់កាលបរិច្ឆេទរួចហើយនោះឡើយ"[5]។

## *II. ឯកសារមិនមាននៅចំពោះអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០១*

2. ទាំង នួន ជា និង ខៀវ សំផន សុទ្ធតែបានដាក់ឯកសារដែលមិនមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង០០២/០១។ ទាំងនេះរួមបញ្ចូលទាំងឯកសារដែលបានដាក់ទៅក្នុងសំណុំរឿង០០២ នៅក្រោយចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ព្រមទាំងឯកសារមិនមាននៅក្នុងសំណុំរឿង០០២។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ឯកសារទាំងនេះគួរត្រូវបានច្រានចោល។

---

[1] **F24** ដីកាកំណត់កាលបរិច្ឆេទសវនាការ, ២ មិថុនា ២០១៥។

[2] **F26** សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ, ១៧ មិថុនា ២០១៥, កថាខណ្ឌ៣(ក)។

[3] **F26** សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ, ១៧ មិថុនា ២០១៥, កថាខណ្ឌ៣(ខ)។

[4] **F26/1/1** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន ស្តីពីសំណើសុំពន្យារពេលសម្រាប់ដាក់សេចក្តីជំទាស់, ត្រង់ទំព័រ៣។

[5] **F26** សេចក្តីណែនាំស្តីពីកិច្ចនីតិវិធីនៃសវនាការ, ១៧ មិថុនា ២០១៥, កថាខណ្ឌ៣(ខ)។

3. អជតក បានសម្រេចថា ពុំមានឯកសារថ្មីណាមួយនឹងត្រូវបានអនុញ្ញាតឡើយចំពោះបណ្តឹងសាទុក្ខ ប្រសិនបើមិនបានបំពេញតាមលក្ខខណ្ឌសាកល្បងចំនួនបី *មានន័យថា* “ភ័ស្តុតាងដែលផ្តល់ជូន៖ (១)ពុំអាចរកបាននៅពេលជំនុំជម្រះ, (២)អាចជាកត្តាកំណត់នាំឱ្យឈានដល់ការធ្វើសេចក្តីសម្រេចក្រោមបណ្តឹងសាទុក្ខ និង(៣)ទាក់ទងនឹងការរកឃើញអង្គហេតុជាក់លាក់ណាមួយដោយអង្គជំនុំជម្រះសាលាដំបូង”[6]។ លើកលែងតែមានភាគីណាមួយបានដាក់ពាក្យសុំដោយអនុលោមតាមវិធាន១០៨(៧) នៃវិធានផ្ទៃក្នុង ហើយអង្គជំនុំជម្រះបានទទួលយកជាភ័ស្តុតាងរួចហើយតែប៉ុណ្ណោះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា គ្មានឯកសារណាមួយដែលមិនមាននៅក្នុងសំណុំរឿងនៅក្នុងពេលមានសាលក្រមនៃសំណុំរឿង០០២/០១ គួរត្រូវបានប្រើប្រាស់ក្នុងការសួរដេញដោលសាក្សីទាំងនេះឡើយ[7]។

4. គេគួរកត់សម្គាល់ផងដែរថា ដោយសារតែអង្គជំនុំជម្រះតុលាការកំពូលមិនធ្លាប់បានលើកឡើងឲ្យបានច្បាស់ពីគោលការណ៍ស្តីពីការប្រើឯកសារ ក្រៅពីអ្វីដែលមាននៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០១ និងដើម្បីរក្សាសិទ្ធិរបស់ពួកគាត់ក្នុងការទទួលនូវភាពស្មើគ្នា សហព្រះរាជអាជ្ញាក៏ធ្លាប់បានដាក់បញ្ចូលផងដែរទៅក្នុងបញ្ជីឯកសាររបស់ខ្លួន ដែលត្រូវបានបន្ថែមទៅក្នុងសំណុំរឿង០០២ បន្ទាប់ពីសាលក្រមនៃសំណុំរឿង០០២/០១ត្រូវបានចេញ។ បើ អជតក អនុវត្តយុត្តិសាស្ត្រពីមុនរបស់ខ្លួនពាក់ព័ន្ធនឹងការទទួលយកឯកសារថ្មីនៅពេលដែលបានដាក់ជូននោះ សហព្រះរាជអាជ្ញាយល់ឃើញថា ការណ៍នេះក៏អាចត្រូវអនុវត្តចំពោះការប្រើប្រាស់ដោយផ្ទាល់ខ្លួននូវឯកសារបែបដូច្នោះផងដែរ។

## *II. “ចម្លើយសារភាព” នៅ ស-២១*

5. បញ្ជីឯកសាររបស់ នួន ជា រួមមាន “ចម្លើយសារភាព” នៅគុក ស-២១[8]។ គេមិនទាន់ដឹងនៅឡើយទេថាតើ នួន ជា មានចេតនាប្រើប្រាស់ឯកសារទាំងនោះដោយរបៀបណា។ ពីមុនមក សហ

[6] **F2/5** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, កថាខណ្ឌ១៦។

[7] ករណីលើកលែងអាចមានចំពោះតែកំណត់ហេតុផ្ទាល់ខ្លួនរបស់សាក្សីប៉ុណ្ណោះ។

[8] ឯកសារចំនួន ៨ ទាក់ទងនឹង SCW-4 (E3/1682 (ភាគខ្លះ) ចម្លើយសារភាពរបស់ ជូ ជេត នៅ ស-២១។ ឯកសារចំនួន ២១ ទាក់ទងនឹង SCW-5 (E3/3989 ចម្លើយសារភាពរបស់ មូល សម្បត្តិ ហៅ រស់ ញឹម នៅ ស-២១)។ និង ឯកសារចំនួន ៣១ ទាក់ទងនឹង SCW-5 (E3/4202 Gina Chon និង ថេត សម្បត្តិ, “នៅក្រោយវាលពិឃាត”), រួមមានទាំងភស្តុតាងអំពីចម្លើយសារភាពរបស់ រស់ ញឹម នៅ ស-២១ ផងដែរ ត្រង់ ENG ERN 00757532។

ព្រះរាជអាជ្ញាធ្លាប់បានលើកបញ្ហាស្តីពីការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម នៅក្នុងការដាក់សារណាមួយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[9] និងក្នុងសំណើមួយសុំឱ្យមានអំណះអំណាងដោយផ្ទាល់មាត់[10]។ ដោយសង្ខេបខ្លឹមសារអំណះអំណាងនោះ គោលជំហររបស់សហព្រះរាជអាជ្ញាគឺថា ច្បាប់ជាតិ និងអន្តរជាតិ រារាំងដោយច្បាស់លាស់ដល់ភាគីមិនឱ្យប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ដើម្បីបង្ហាញសក្ខីកម្មពីការពិតនៃរឿងរ៉ាវនានាដែលបាន"ឆ្លើយសារភាព"។ យ៉ាងណាក៏ដោយ សេចក្តីថ្លែងនានាអាចត្រូវបានប្រើប្រាស់ ដើម្បីបង្ហាញសក្ខីកម្មពីអង្គហេតុពាក់ព័ន្ធដទៃទៀតដែលមិនពឹងផ្អែកលើការពិតនៃ "ចម្លើយសារភាព" ដូចជាអង្គហេតុដែលថា ពួកអ្នកទោសត្រូវបានចោទប្រកាន់ និងត្រូវបានសួរចម្លើយពីការលាក់បាំង ឬការខកខានមិនបានសម្លាប់ពួកមន្ត្រីរដ្ឋការ លន់ នល់ ឬភស្តុតាងបន្ថែមទៀតស្តីពីការសម្លាប់ពួកមន្ត្រីរដ្ឋការ លន់ នល់ ត្រូវស្ថិតនៅក្នុងគោលនយោបាយស្តីពីខ្មាំងនៃរបប[11]។

6. តាមរយៈអង្គហេតុជាក់លាក់ទាំងឡាយនៃសំណុំរឿងនេះ ការហាមឃាត់នេះអាចអនុវត្តយ៉ាងច្បាស់លាស់ក្នុងការរារាំង នួន ជា ដែលភស្តុតាងក្នុងសំណុំរឿងលេខ០០២/០២ នឹងបង្ហាញថាគាត់បានគ្រប់គ្រងនៅគុក ស-២១ ដែលជាកន្លែងអ្នកទោសត្រូវបានធ្វើទារុណកម្មជាប្រចាំ និងគួរឱ្យភ័យខ្លាច មិនឱ្យប្រើប្រាស់ចម្លើយសារភាពដើម្បីបង្ហាញថារឿងរ៉ាវដែល "បានសារភាព" ជាការពិតឡើយ។ ពីព្រោះការណ៍នេះអាចលើកពីគោលបំណងដែលថា អំពើទារុណកម្មជាការធ្វើឱ្យឈឺចាប់ ដើម្បីធ្វើយុត្តិកម្មឧក្រិដ្ឋកម្មទាំងឡាយរបស់របបនោះ។

7. ទោះជាយ៉ាងណា សហព្រះរាជអាជ្ញាបានទទួលស្គាល់នៅក្នុងអំណះអំណាងរបស់ខ្លួនថា ដើម្បីទាត់ចោលភស្តុតាងដែលជាប់ពាក់ព័ន្ធខ្លាំងដោយផ្អែកលើការទប់ស្កាត់អំពើទារុណកម្មនោះ អ្នកស្វែងរកការពិតត្រូវរកឱ្យឃើញថាអំពើទារុណកម្មពិតជាការឈឺចាប់ និងថាចម្លើយជាក់លាក់នោះបានមកពីការធ្វើទារុណកម្ម។ ភស្តុតាងនោះត្រូវបានរំពឹងទុកថាមានច្រើន នៅក្នុងសំណុំរឿងលេខ

---

[9] **E350/1** សារណារបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការអនុវត្តអនុសញ្ញាប្រឆាំងនឹងទារុណកម្មចំពោះចម្លើយសារភាពរបស់មន្ទីរ ស-២១ និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងការសួរចម្លើយអ្នកទោស, ២១ ឧសភា ២០១៥។

[10] **E1/304.1** ប្រតិចារឹក 09.13.48-09.34.31។

[11] បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ក៏មានរួមបញ្ចូលផងដែរនូវសេចក្តីថ្លែងដែលបានមកពី ស-២១ ដែលសហព្រះរាជអាជ្ញាអាចនឹងប្រើប្រាស់នៅក្នុងអំឡុងពេលនៃការស្តាប់ចម្លើយសាក្សីទាំងនេះ ក៏ប៉ុន្តែត្រូវស្ថិតនៅក្នុងដែនកំណត់នៃគោលជំហរដែលបានបញ្ជាក់ខាងលើ - គឺគ្មានអ្វីដែលនឹងត្រូវបានស្នើឱ្យបង្ហាញសក្ខីកម្មពីការពិតនៃរឿងរ៉ាវដែលបានសារភាពតាមរយៈទារុណកម្មនោះទេ។

០០២/០២ ដែលនឹងដេញដោលអំពីឧក្រិដ្ឋកម្មនៅ ស-២១ ប៉ុន្តែភ័ស្តុតាងនៃការធ្វើការធ្វើទារុណកម្ម នោះមានកម្រិតនៅចំពោះមុខ អជតក ក្នុងសំណុំរឿងលេខ០០២/០១។ សហព្រះរាជអាជ្ញា យល់ឃើញថា ទោះបីជាភាគច្រើនមិនមាននៅក្នុងឯកសារនៃសំណុំរឿងលេខ០០២/០១ ក៏ដោយ ក៏ភ័ស្តុតាងដែលមាន ភាគច្រើនគឺថា បុរស ស្ត្រី និងកូនក្មេងជាច្រើន ត្រូវបានឃុំឃាំងនៅ ស២១ គឺជាជនរងគ្រោះនៃអំពើទារុណកម្ម ដែលស្ថិតនៅក្នុងអត្ថន័យនៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម[12]។ ដើម្បីគោលបំណងនៃសវនាការនៃ អជតក សហព្រះរាជអាជ្ញាមានចេតនាបញ្ជាក់លើអង្គហេតុនេះ ហើយស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូលកំណត់ ប្រសិនបើការណ៍នេះ គឺជាអង្គហេតុកំពុងតវ៉ាក្នុង ចំណោមភាគីទាំងឡាយ ឬអាចត្រូវបានដោះស្រាយដោយបញ្ញត្តិច្បាប់៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | |

[12] មាត្រា១ នៃអនុសញ្ញានេះកំណត់និយមន័យការធ្វើទារុណកម្មថា "អំពើទាំងឡាយណា ដែលនាំឲ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង **ទោះផ្លូវកាយ ឬផ្លូវចិត្តក្ដី** ដែលត្រូវបានបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយដូចជា ទាញយកព័ត៌មានពីជននោះ ឬតតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះ ចំពោះអំពើណាមួយដែលជននោះ ឬតតិយជនណាម្នាក់បានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬបំភិតបំភ័យ ឬបង្ខិតបង្ខំជននោះ ឬតតិយជនណាម្នាក់ ឬដើម្បីមូលហេតុណាផ្សេងទៀតដែលផ្អែកលើការរើសអើងណាមួយ បើការឈឺចាប់ ឬការរងទុក្ខ បង្កដោយមន្ត្រីសាធារណៈ ឬជនផ្សេងទៀត តាមការញុះញង់ ឬការព្រមព្រៀង ឬផ្ដើមគំនិតរបស់មន្ត្រីសាធារណៈ ឬជនផ្សេងទៀតដែលបំពេញតួនាទីជាផ្លូវការ។" (គូសបញ្ជាក់បន្ថែម។)